# ជំពូកទី ១: សេចក្តីផ្តើម

## ១.១ លក្ខណៈទូទៅនៃគំរោង

នៅក្នុងពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅមានការខ្វះខាតយ៉ាងខ្លាំងទៅលើការផ្គត់ផ្គង់អគ្គិសនីសំរាប់ការប្រើប្រាស់តាមលំនៅដ្ឋាន និងឧស្សាហកម្ម។ ពីមួយឆ្នាំទៅមួយឆ្នាំ តំរូវការប្រើប្រាស់ថាមពលអគ្គិសនីមានការកើនឡើងយ៉ាងខ្ពស់ រីឯអ្នកផ្គត់ផ្គង់ឬអ្នកផលិតអគ្គិសនីមានចំនួនកំណត់ និងមានតំលៃប្រើប្រាស់ខ្ពស់បើប្រៀបធៀបទៅនឹងប្រទេសជិតខាង។ ការផលិតថាមពលប្រចាំឆ្នាំដោយអគ្គិសនីកម្ពុជាគឺ ៩០៥.៩២ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ២០០៥ និង ១១០៦.៤៧ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ២០០៦ និងបាននាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាងដូចជា ប្រទេសវៀតណាម និងថៃ ដែលមានថាមពលសរុប ២៣.៨៨ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ២០០៥ និង ៤២.១៤ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ ២០០៦ តែទោះជាយ៉ាងណាក៏ដោយតំរូវការប្រើប្រាស់ភ្លើងអគ្គិសនីគឺមានទំហំធំធេងណាស់រហូតទៅដល់ ២៦៩៩ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ ២០១០ និង ៨១៧៥ លានគីឡូវ៉ាត់ម៉ោងក្នុងឆ្នាំ ២០២០ នេះបើយោងទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ថាមពលអគ្គិសនីកម្ពុជាឆ្នាំ២០០៦ និងរបាយការណ៍ស្តីអំពីវិស័យថាមពលនៃព្រះរាជាណាចក្រកម្ពុជាសំរាប់ឆ្នាំ ២០០៦ ដែលបានរៀបរៀងដោយអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ខែកក្កដា ឆ្នាំ២០០៧ ។ ទន្ទឹមនឹងនេះការកសាងគំរោងវារីអគ្គិសនីខ្នាតតូចនិងមធ្យម គឺត្រូវបានលើកទឹកចិត្តឱ្យសាងសង់និងប្រតិបត្តិការផងដែរ ។ ឧទាហរណ៍បច្ចុប្បន្ននេះមានរោងចក្រវារីអគ្គិសនីចំនួនពីរប៉ុណ្ណោះ ដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា ហើយមានសមត្ថភាពផលិតទាប/តិច គឺរោងចក្រវារីអគ្គិសនីអូរជុំនៅក្នុងខេត្តរតនគីរី (កំលាំង ១ មេហ្គាវ៉ាត់) និង រោងចក្រវារីអគ្គិសនីស្ទឹងច្រាលនៅក្នុងខេត្តកំពង់ស្ពឺ (គីរីរម្យ១ មានកំលាំង ១៣ មេហ្គាវ៉ាត់)។ ក្រៅពីនេះនៅមានគំរោងរោងចក្រវារីអគ្គិសនីកំចាយ ដែលមានកំលាំង ១៩៣.២ មេហ្គាវ៉ាត់ ជាគំរោងដែលកំពុងសាងសង់ និងចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ ២០១០ ខាងមុខនេះ។ ចំណែករោងចក្រអគ្គិសនីផ្សេងទៀត គឺស្ថិតក្នុងផែនការ និងកំពុងសិក្សានៅឡើយ ។

ផលិតកម្មអគ្គិសនីនៅក្នុងប្រទេសកម្ពុជាភាគច្រើនបានមកពីម៉ាស៊ីនភ្លើងដែលប្រើប្រេងឥន្ធនៈ ហើយតំលៃប្រេងឥន្ធនៈនៅលើទីផ្សារមានតំលៃខ្ពស់ដែលជាហេតុធ្វើអោយតំលៃភ្លើងអគ្គិសនីមានតំលៃខ្ពស់ផងដែរ សំរាប់អ្នកប្រើប្រាស់។ បច្ចុប្បន្នអត្រាតំលៃអគ្គិសនីរបស់អគ្គិសនីកម្ពុជា “EDC” គឺ ០.១៥ ដុល្លា/គីឡូវ៉ាត់ម៉ោង សំរាប់អ្នកប្រើប្រាស់តិច និង ០.២២៥ ដុល្លា/គីឡូវ៉ាត់ម៉ោង សំរាប់អ្នកប្រើប្រាស់ច្រើន ។ ចំពោះអ្នកផ្គត់ផ្គង់អគ្គិសនីឯកជន អត្រានៃតំលៃប្រើប្រាស់គឺ ០.៣០-០.៦០ ដុល្លា/គីឡូវ៉ាត់ម៉ោង នៅទីកន្លែងខ្លះតម្លៃភ្លើងអគ្គិសនីឡើងរហូតដល់ទៅ ១ ដុល្លា/គីឡូវ៉ាត់ម៉ោង ឧទាហរណ៍ ដូចជាទីប្រជុំជនស្រុកថ្មបាំងមានតម្លៃ ១ដុល្លា ក្នុង១គីឡូវ៉ាត់ម៉ោង ។ ខណៈដែលការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាងមានកំណត់និងគ្មាននិរន្តរភាព។ ក្នុងតារាង១.១-១បានបង្ហាញពីតម្លៃប្រើប្រាស់ភ្លើងអគ្គិសនីក្នុងទីប្រជុំជនមួយចំនួននៅជិតតំបន់គំរោង ដែលអ្នកចែកចាយមានលិខិតអនុញ្ញាតពីអាជ្ញាធរអគ្គិសនីកម្ពុជាក្នុងឆ្នាំ ២០០៦។

Draft

តារាង ១.១-១: តារាងតម្លៃនៃការប្រើប្រាស់ថាមពលអគ្គិសនីក្នុងទីប្រជុំជនមួយចំនួនជិតតំបន់គំរោង

| ខេត្ត | តំបន់មាន ការផ្គត់ផ្គង់ភ្លើង | តម្លៃភ្លើងអគ្គីសនីក្នុង១គីឡូវ៉ាត់ម៉ោង | | លក្ខខ័ណ្ឌអ្នកប្រើប្រាស់ |
|---|---|---|---|---|
| | | រៀល | ដុល្លា | |
| ព្រះសីហនុ | ខ័ណ្ឌព្រៃនប់ | ២៣០០ | 0.៥៦ | រាល់អតិថិជនទាំងអស់ |
| | ផ្សារវាលរិញ | ១៧០០ | 0.៤១ | រាល់អតិថិជនទាំងអស់ |
| | វាលរិញ | ១៨៥0 | 0.៤៥ | រាល់អតិថិជនទាំងអស់ |
| កោះកុង | ស្រែអំបិល | ២៣០០ | 0.៥៦ | រាល់អតិថិជនទាំងអស់ |
| កំពង់ស្ពឺ | ត្រពាំងក្រឡឹង | ៣000 | 0.៧៣ | រាល់អតិថិជនទាំងអស់ |
| | ក្រុងកំពង់ស្ពឺ | ២៧០០ | 0.៦៦ | រាល់អតិថិជនទាំងអស់ |

ប្រភព: ដកស្រង់ចេញពីរបាយការណ៍លើវិស័យថាមពលអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាសំរាប់ឆ្នាំ២០០៦. ចងក្រងដោយអាជ្ញាធរអគ្គិសនីកម្ពុជា ខែកក្កដា ឆ្នាំ២០០៧។

ទោះជាយ៉ាងណាក៏ដោយការអភិវឌ្ឍថាមពលអគ្គិសនីគឺមានសារៈសំខាន់ណាស់ ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា។ ប៉ុន្តែការផ្គត់ផ្គង់ថាមពលអគ្គិសនីដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា គឺមានប្រព័ន្ធបែងចែកដាច់ដោយឡែកពីគ្នា ដែលពុំតភ្ជាប់គ្នាពីមួយទៅមួយៗ និងមានច្រើនជាង ៩៥ភាគរយ នៃថាមពលអគ្គិសនីផលិតសរុប បានមកពីរោងចក្រថាមពលដើរដោយប្រេងឥន្ធនៈ។ ជាងនេះទៅទៀតមានតែ ១៨ភាគរយនៃគ្រួសារសរុបនៅក្នុងប្រទេសកម្ពុជាបានទទួលភ្លើងអគ្គិសនីប្រើប្រាស់ តួលេខនេះយោងតាមរបាយការណ៍អំពីវិស័យថាមពលអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាសំរាប់ឆ្នាំ២០០៦ ដែលបានចងក្រងដោយអាជ្ញាធរអគ្គិសនីកម្ពុជា ខែកក្កដា ឆ្នាំ២០០៧។

ហេតុដូចនេះហើយគំរោងអភិវឌ្ឍន៍រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ អាចជាគំរោងអភិវឌ្ឍន៍ថាមពលអាទិភាពមួយក្នុងចំណោមគំរោងអាទិភាពមួយចំនួន ដែលឆ្លើយតបទៅនឹងតំរូវការថាមពលរបស់ប្រទេសក្នុងឆ្នាំខាងមុខៗព្រមទាំងទ្រទ្រង់និន្នាការនៃការរីកចំរើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និង ការកាត់បន្ថយភាពក្រីក្រ។

## ១.២ គោលបំណងរបាយការណ៍

ដោយផ្អែកតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបាន ឡាយព្រះហស្តលេខាដោយសម្តេចព្រះ **នរោត្តម សីហនុ** (២៤ ធ្នូ ១៩៩៦) និង អនុក្រឹត្យស្តីពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** (ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩) និងការផ្តល់អនុសាសន៍របស់ក្រសួងបរិស្ថាន និងអន្តរក្រសួង ក្នុងការយល់ព្រមលើរបាយការណ៍វាយតំលៃ

ហេតុប៉ះពាល់បរិស្ថានដំបូងរបស់គំរោងវារីអគ្គិសនីស្ទឹងតាតៃនៅ ខែមិនា ឆ្នាំ២០០៨ គំរោងនេះត្រូវបានចាត់ទុកជាគំរោងខ្នាតធំមួយ ហើយទាមទារឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ។

គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីបង្ហាញលទ្ធផលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានទាំងវិជ្ជមាន និងអវិជ្ជមានរបស់គំរោងវារីអគ្គិសនីរួមទាំងហេតុប៉ះពាល់ដោយផ្ទាល់ និងហេតុប៉ះពាល់ដោយប្រយោលទៅលើធនធានធម្មជាតិ និង ធនធានសង្គមទាំងនៅក្នុង និងនៅជុំវិញតំបន់គំរោង ។

ការសិក្សានឹងពិនិត្យមើលពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយរៀបចំនូវវិធានការកាត់បន្ថយសំរាប់ហេតុប៉ះពាល់អវិជ្ជមាននិមួយៗនៅពេល រចនាប្លង់ ពេលសាងសង់ និងដំណើរការគំរោង ។ ការវាយតំលៃត្រូវបានធ្វើឡើងដោយអនុលោមទៅតាមច្បាប់នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងបទបញ្ញត្តិ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

របាយការណ៍សិក្សា EIA ពេញលេញនឹងត្រូវដាក់រួមគ្នាជាមួយ និងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង (Feasibility Study Report) ជូនទៅក្រសួងបរិស្ថាន (MoE) និងអន្តរក្រសួង ដើម្បីអនុម័តមុនពេលគំរោងចាប់ផ្តើមសាងសង់ និងប្រតិបត្តិការ ។ ទន្ទឹមនោះដែរ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង និងប្លង់វិស្វកម្មលំអិត នឹងត្រូវដាក់ជូន ទៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME) ដែលជាសម៊ីក្រសួង លើគំរោងនេះដើម្បីអនុម័តលើលក្ខណៈបច្ចេកទេស និងការងារវិស្វកម្មផ្សេងៗ ។ ឯកសារអនុម័តទាំងពីរនឹងរួមបញ្ចូលគ្នាក្លាយជាឯកសារសំខាន់មួយដោយរួមជាមួយឯកសារវិនិយោគទុនផ្សេងៗទៀតដែលត្រូវដាក់ស្នើទៅរាជរដ្ឋាភិបាលកម្ពុជា (RGC) តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ដើម្បីផ្តល់សិទ្ធិអនុញ្ញាតឱ្យដល់ក្រុមហ៊ុនវិនិយោគ (CHMC) ក្នុងការអនុវត្តន៍គំរោង ។

Draft

## ១.៣ គោលបំណងសេដ្ឋកិច្ចសង្គមនិងបរិស្ថានរបស់គំរោង

គោលបំណងចំបងរបស់គំរោង គឺទាញយកផលប្រយោជន៍ពីធនធានបរិស្ថាន ជាពិសេសធនធានទឹកពីស្ទឹងតាតៃ និងស្ទឹងកែប នៅក្នុងខេត្តកោះកុង ។ ទន្ទឹមនោះដែរ ទឹកដែលស្តាក់ទុកនៅក្នុងអាងស្តុកទឹកជួយសំរួលកំពស់ទឹកជំនន់ធំនៅខ្សែទឹកខាងក្រោម កើនជំរកទឹកក្រោមដី អាចផ្តល់ទឹកសំរាប់សកម្មភាពកសិកម្មនានា និងងាយស្រួលចូលប្រភពទឹក (ពុំចោទខ្លាំងដូចមុន) ដល់សត្វព្រៃក្នុងតំបន់នោះ ។

ម្យ៉ាងវិញទៀតនៅក្នុងចំណងជើងតូច "៤.២.២ ទឹកសំរាប់ថាមពល" នៃគោលនយោបាយធនធានទឹកថ្នាក់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា បានបង្ហាញប្រាប់ថា ដើម្បីទទួលបានផលប្រយោជន៍យ៉ាងធំសំបើមពីប្រភពធនធានទឹក រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចខាងក្រោមៈ

១- ជំរុញ និង លើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវអភិវឌ្ឍន៍វារីអគ្គិសនីខ្នាតតូច ខ្នាតមធ្យម និង ខ្នាតធំ ទៅលើសក្តានុពលនៃការប្រើប្រាស់ទឹកសំរាប់វារីអគ្គិសនីរួមទាំង តំលៃ និង គុណប្រយោជន៍ ។

២- ជំរុញការវិនិយោគ និងការធ្វើអាជីវកម្មគ្រប់ខ្នាតក្នុងការអភិវឌ្ឍវារីអគ្គិសនីទាំងអស់ដើម្បីមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ។

គោលបំណងនៃសេដ្ឋកិច្ចសង្គមរបស់គំរោងសាងសង់រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ គឺដើម្បីបំពេញតំរូវការថាមពលសំរាប់រយៈពេលមធ្យម និង រយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា។ គំរោងនេះក៏ឆ្លើយតបដោយផ្ទាល់ទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទីបី ត្រង់ចំនុចចតុកោណទី២ មុំទី៣ “*ការអភិវឌ្ឍន៍វិស័យថាមពលនិងបណ្តាញអគ្គិសនី* ” ដែលចែងថា ÷ *បន្តអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងក្នុងតំលៃសមរម្យ ទៅនឹងតំរូវការនៃការប្រើប្រាស់ ដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ គឺ ជារបៀបវារៈដ៏សំខាន់បំផុតមួយនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ ទៅលើការទាក់ទាញឱ្យមានការចូលរួមរបស់ផ្នែកឯកជននៅក្នុងផលិតកម្មអគ្គិសនី ផ្គត់ផ្គង់អគ្គិសនីពិសេសនៅតាមបណ្តាទីរួមខេត្ត និងទីប្រជុំជនសំខាន់ៗ ការអនុវត្តន៍អគ្គិសនីភាវូបនីយកម្មតំបន់ជនបទប្រកបដោយគុណភាព និងមានតំលៃទាបសមរម្យ ព្រមទាំងគំរោងតភ្ជាប់ខ្សែបញ្ជូនថាមពលពីប្រទេសជិតខាង។*

គោលបំណងសំខាន់នៃបរិស្ថាននិងសេដ្ឋកិច្ចសង្គម គឺដើម្បីធានាបានផងដែរថា តុល្យភាពត្រឹមត្រូវរវាងការផលិតថាមពលដែលផ្តល់ជាហេតុប៉ះពាល់ជាវិជ្ជមានដល់សេដ្ឋកិច្ចជាតិ និង ហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមដែលវាបង្កជាពិសេសទៅលើធនធានក្នុងតំបន់មូលដ្ឋាននិងរបស់សហគមន៍។ នៅកន្លែងដែលមានផលប៉ះពាល់អវិជ្ជមានដល់ធនធានបរិស្ថាន និងសង្គមក្នុងតំបន់ត្រូវបានកត់សំគាល់ច្បាស់លាស់ នោះវិធានការសំណងសមរម្យត្រូវតែបានផ្តល់ឱ្យប្រសិនបើគំរោងធ្វើការសាងសង់។

Draft

## ១.៤ ទំហំដែន និង មាតិកាសង្ខេបរបាយការណ៍

ទំហំដែននៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) គ្របដណ្តប់ទាំងគុណប្រយោជន៏របស់បរិស្ថាន និងសង្គម លេចចេញពីគ្រប់ទិដ្ឋភាពទាំងអស់របស់គំរោងនៅក្នុងការកំណត់យ៉ាងទូលំទូលាយនៃចំណាត់ថ្នាក់ធនធានបរិស្ថាន និង គុណតំលៃរបស់វារួមមានៈ បរិស្ថានរូបសាស្ត្ររួមមាន ដី ទឹក និង បរិយាកាស ។ បរិស្ថានជីវសាស្ត្ររួមមាន សត្វ និងរុក្ខជាតិ ដែលរស់នៅលើផែនដី និងនៅក្នុងទឹក ព្រមជាមួយនឹងជំរករបស់វា ។ បរិស្ថានសង្គម ដែលរាប់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន សេវាកម្ម និងមធ្យោបាយបំរើឱ្យសុខមាលភាព ការងារ ការអប់រំ ការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ព្រមទាំងតំបន់វប្បធម៌ វត្ថុបុរាណ និងគុណភាពតំលៃនៃការរស់នៅ ក្នុងតំបន់គំរោង។

មាតិកាសង្ខេបនៃរបាយការណ៏នេះរួមមានដប់ជំពូកដូចតទៅៈ ប្រវត្តិរបស់គំរោងមានរៀបរាប់នៅជំពូកទី១ ។ ក្របខ័ណ្ឌច្បាប់ដែលទាក់ទងទៅនឹងប្រភេទនិងសកម្មភាពទាំងឡាយរបស់គំរោងមានបង្ហាញក្នុងជំពូកទី២។ ការពិណនាជាទូទៅពីសមាសធាតុរបស់គំរោងមានរៀបរាប់នៅក្នុងជំពូកទី៣។ ស្ថានភាពដើមដែលទាក់ទងទៅនឹងធនធានបរិស្ថានដែលមានស្រាប់មានរៀបរាប់ក្នុងជំពូកទី៤។ ជំរើសនានារបស់គំរោងមានបង្ហាញនៅក្នុងជំពូកទី៥ ដែលលើកឡើង

ពីការធ្វើយុត្តិកម្មសំរាប់ទំរង់គំរោងស្នើសុំធៀបទៅនឹងលទ្ធភាពផ្សេងៗទៀត ។ នៅក្នុងជំពូកទី៦ មានរៀបរាប់ពីការវាយតំលៃទៅលើហេតុប៉ះពាល់បរិស្ថាននិងវិធានការបន្ធូរបន្ថយ ។ ការជួបប្រជុំជាសាធារណៈនិងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគំរោង និងប្រជាជនដែលទទួលរងផលប៉ះពាល់ មានរៀបរាប់នៅក្នុងជំពូកទី៧ ។ ផែនការគ្រប់គ្រងបរិស្ថាន (EMP) មានរៀបចំនៅក្នុងជំពូកទី៨ ហើយការវាយតំលៃពីសេដ្ឋកិច្ចសំរាប់គំរោងមានពណ៌នានៅក្នុងជំពូកទី៩។ នៅចុងបញ្ចប់គឺជំពូកទី១០ ដែលមានរៀបរាប់ពីសេចក្តីសន្និដ្ឋាន និង អនុសាសន៍ទៅលើការសិក្សាពីវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ទាំងមូល ។

## ១.៥ វិធីសាស្ត្រ

មាតិកានៃរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) គឺអនុលោមទៅតាមអនុក្រឹត្យស្តីពីកិច្ចដំណើរ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា (លេខ ៧២ អនក្រ.បក ខែសីហា ឆ្នាំ ១៩៩៩) និងគោលការណ៍ណែនាំសំរាប់រៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន ហើយស្របទៅតាមគោលការណ៍ណែនាំវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ខែសីហា ២០០៣ ។

ការធ្វើ EIA គិតគូរទៅលើអន្តរអំពើរវាងសមាសធាតុគំរោង និងលក្ខណៈបរិស្ថាន។ អន្តរអំពើផ្តល់នូវការកើតឡើងទាំងហេតុប៉ះពាល់វិជ្ជមាននិងអវិជ្ជមាន។ ផលប្រយោជន៍ផ្សេងៗត្រូវបានកត់សំគាល់ និងក្នុងករណីខ្លះមានដាក់ក្នុងការវិភាគសេដ្ឋកិច្ចបរិស្ថាន។ ហេតុប៉ះពាល់អវិជ្ជមានត្រូវបានកាត់បន្ថយតាមរយៈការរៀបចំប្លង់គំរោង និងតាមរយៈការអនុវត្តការងារ ។ វិធានការទូទាត់ ឬ សំណងតាមទំរង់ផ្សេងៗនឹងត្រូវធ្វើជាចាំបាច់សំរាប់ហេតុប៉ះពាល់ដែលមិនអាចគណនាបាន។ ហេតុប៉ះពាល់អវិជ្ជមាន ក៏អាចត្រូវបង្ហាញជាតួលេខនៅក្នុង ការវិភាគសេដ្ឋកិច្ចបរិស្ថានផងដែរ។ ដើម្បីធានាបានពីការរៀបចំឱ្យបានល្អ និង មានភាពរលូនសំរាប់ការសិក្សា EIA ពេញលេញវិធីសាស្ត្រទូទៅមានរៀបរាប់ដូចខាងក្រោមៈ

***១. ការប្រមូលទិន្នន័យ និង ការពិនិត្យមើលរបាយការណ៍បច្ចេកទេស***

- ការប្រមូលទិន្នន័យជាក់ស្តែង និងទិន្នន័យដែលមានស្រាប់នៅ ទីក្រុងភ្នំពេញ និងខេត្តកោះកុង ទាក់ទងទៅនឹងច្បាប់ គោលនយោបាយ បទបញ្ញត្តិ ជីវៈចំរុះ ជីវភាពរស់នៅដែលពឹងពាក់លើការ នេសាទ និងប្រមូលអនុផលព្រៃឈើ ទិន្នន័យសេដ្ឋកិច្ចសង្គម និងទិន្នន័យផ្សេងទៀតទាក់ទងទៅ នឹងគំរោង ។
- ពិនិត្យមើលលើរបាយការណ៍សមិទ្ធិលទ្ធភាពរបស់គំរោង និងរបាយការណ៍ប្លង់វិស្វកម្មលំអិត និងឯកសារទាក់ទងផ្សេងទៀតទៅនឹងការអនុញ្ញាតិឱ្យវិនិយោគរបស់គំរោង ។

## ២. ការជួបប្រជុំ និង ការពិគ្រោះយោបល់

- ការជួបប្រជុំ និងការពិគ្រោះយោបល់ជាមួយស្ថាប័នសំខាន់ៗដែលទាក់ទងទៅនឹងគំរោងត្រូវ បានធ្វើឡើង នៅទីក្រុងភ្នំពេញ និង ខេត្តកោះកុង ដូចជា សាលាខេត្តកោះកុង, មន្ទីរបរិស្ថាន, មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល, មន្ទីរធនធានទឹក និង ឧតុនិយម, មន្ទីរទេសចរណ៍, មន្ទីរកសិកម្ម ,អង្គការអភិរក្សអន្តរជាតិ (CI), WildAid/Wildlife Alliance, រដ្ឋបាលជលផល, សាលាស្រុកថ្មបាំង, សាលាស្រុកកោះកុង, អង្គការសង្គ្រោះសត្វព្រៃ កម្ពុជា (SCW), អង្គការឃែរកម្ពុជា, ខណ្ឌរដ្ឋបាលព្រៃឈើ, និង Oxfam America ។
- ការប្រជុំ និង ពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ឬអ្នកភូមិនៅក្នុងតំបន់ទទួលរងផលប៉ះពាល់ផ្នែក ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមរបស់គំរោងរួមមាន ឃុំឫស្សីជ្រុំ ស្ថិតនៅក្នុងស្រុកថ្មបាំង និង ឃុំតាតៃក្រោម ស្ថិតក្នុងស្រុកកោះកុង ។

## ៣. ការចុះអង្កេតទៅលើធនធានធម្មជាតិ

- ភូគព្ភសាស្ត្រ និង ដី (ទិន្នន័យពីរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព/សិក្សាលំអិតរបស់គំរោង)
- ការសិក្សាលើធនធានព្រៃឈើ មានការថតរូបភាពពីលើអាកាសអំឡុងពេលសិក្សាចាប់ពី ខែមករា ដល់កុម្ភៈ ២០០៩ ដែលមានចំនួនសរុប ២០ផ្ទាំង ដែលទំហំផ្ទៃរូបថតមួយផ្ទាំងៗគឺ ១គ.ម$^{២}$ ការចុះរាប់ ព្រៃឈើតាមប្រភេទព្រៃ ការគណនាជីវម៉ាស់និងការិតស្រូបកាបូនអុកស៊ីត និង ការគណនាជាទឹកប្រាក់ ពីតំលៃរូបសាស្ត្រ និងតំលៃបរិស្ថាន ។
- ការសិក្សាពីសត្វព្រៃ និងជំរកព្រៃឈើនៅក្នុងតំបន់អាងស្តុកទឹក (វិធីសាស្ត្រសិក្សាលំអិតទៅលើ ព្រៃឈើ និង សត្វព្រៃ មានរៀបរាប់នៅក្នុងឯកសារភ្ជាប់ទី ២) ។
- ត្រី និង ប្រភេទវារីភាវរស់នៅក្នុងស្ទឹងផ្នែកខាងលើ និង ខាងក្រោមនៃទីតាំងគំរោង និង នៅក្នុងអាង ស្តុកទឹក(វិធីសាស្ត្រសិក្សាលំអិតមានរៀបរាប់នៅក្នុងរបាយការណ៍សិក្សាត្រី, ក្នុងឯកសារភ្ជាប់ទី ៣) ។
- ការធ្វើតេស្ត ឬការពិនិត្យគុណភាពទឹក: ការធ្វើតេស្តនៅទីវាល ការយកគំរូសំណាកទឹក និង ការធ្វើវិភាគក្នុងមន្ទីរពិសោធន៍នៅភ្នំពេញ (មន្ទីរពិសោធន៍គុណភាពទឹករបស់ក្រសួងបរិស្ថាន និង ក្រសួងធនធានទឹក) ។

## ៤. ការចុះអង្កេតទៅលើធនធានសង្គម

- ដីប្រើប្រាស់: មានប្រើផែនទី JICA ឆ្នាំ ២០០៣ មាត្រដ្ឋាន ១:១០០000 Landsat (TM) ឆ្នាំ ២000 រូបថតពីលើអាកាសឆ្នាំ ២០០១-២០០២ នឹងត្រូវបានយកមកប្រើ ហើយនឹងត្រូវបានប្រមូល ទិន្នន័យពីអាជ្ញាធរ ឃុំ ស្រុក នៅក្នុង ខេត្តកោះកុង ផងដែរ ។

Draft

- ប្រជាពលរដ្ឋនៅក្នុងតំបន់គំរោង និងកំណត់ចំនួនប្រជាជនដែលរងផលប៉ះពាល់: ការចុះអង្កេតដល់ទីតាំង ក្នុងស្រុកថ្មបាំង និងស្រុកកោះកុង និងការសំយោគយកឯកសារមានស្រាប់ពីទិន្នន័យឃុំ។
- ការតាំងទីលំនៅសារជាថ្មី, ប្រសិនបើមាន។
- សកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់សហគមន៍នៅក្នុងតំបន់គំរោង: ការចុះអង្កេតតាមភូមិឃុំផ្ទាល់ និងការសំយោគយកឯកសារមានស្រាប់ដែលពាក់ព័ន្ធ ហើយវិធីសាស្ត្រលំអិតមានបង្ហាញនៅក្នុងរបាយការណ៍សិក្សាសេដ្ឋកិច្ចសង្គមក្នុងឯកសារភ្ជាប់ទី ៤។
- ហេដ្ឋារចនាសម្ព័ន្ធបំរើឱ្យការប្រើប្រាស់របស់មនុស្ស និង គុណភាពនៃជីវិតរស់នៅ: ការចុះអង្កេតតាមភូមិ ឃុំផ្ទាល់ និងការសំយោគ យកឯកសារមានស្រាប់ដែលពាក់ព័ន្ធ។

## ៥. ការវិភាគ និង ការវាយតំលៃពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់គំរោងទាំងមូល

- ប្រើតារាងឆេកលីសសំរាប់គំរោងវារីអគ្គិសនី
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលរៀបចំប្លង់គំរោង
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលសាងសង់គំរោង
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលប្រតិបត្តិគំរោង

## ៦. ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន EIA

- របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានមានទំរង់ទៅតាមគោលការណ៍នាំរបស់ក្រសួងបរិស្ថាន និងគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងផ្អែកលើឯកសារយោង (ToR) របស់ក្រុមហ៊ុន CHMC/CTHL/NWH, មើលក្នុងឯកសារភ្ជាប់ទី ១។
- ផែនទី GIS និង រូបថតត្រូវបានដាក់បញ្ចូល។
- ការប៉ាន់ប្រមាណទុនវិនិយោគសរុប ការស្នើមូលនិធិបរិស្ថាន និងផលប្រយោជន៍គំរោងត្រូវបានលើកបង្ហាញផងដែរ។
- ការដាក់បញ្ចូលវិធានការបន្ធូរបន្ថយដើម្បីកាត់បន្ថយទំហំនៃហេតុប៉ះពាល់ អំឡុងពេលរៀបចំប្លង់ ដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិគំរោង។
- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន ដើម្បីប្រើប្រាស់កំឡុងពេលសាងសង់ និងប្រតិបត្តិការ។

Draft

ដ្យាក្រាមសង្ខេបវិធីសាស្ត្រនៃការសិក្សារៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ សំរាប់គំរោងវារីអគ្គិសនីស្ទឹងតាតៃ ក្នុងខេត្តកោះកុង ប្រទេសកម្ពុជា




Draft